**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៤៧៩
ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣
**សាលដីកា**
លេខៈ១៦១
ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ........... ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............ ជាចៅក្រម
៣-លោក ............ ជាចៅក្រមរបាយការណ៍
៤-លោក ............ ជាចៅក្រម
៥-លោក ............... ជាចៅក្រម

**ក្រឡាបញ្ជី**
-អ្នកស្រី ..................

**តំណាងមហាអយ្យការ**
-លោក............ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ១៤១(ឈ) ចុះថ្ងៃទី១៩-៩-០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥០៦ ចុះថ្ងៃទី១៣-៨-០៣ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះឡូវណារ (ជាដើមបណ្តឹងសាទុក្ខ) ភេទស្រីអាយុ៤៣ ឆ្នាំជាតិខ្មែរ របររកស៊ីមេផ្ទះ ទីលំនៅភូមិស្ទឹងថ្មី ឃុំស្វាយដង្គំ ស្រុមសៀមរាប ខេត្តសៀមរាប ។

**មេធាវី លោក ............**

និងចុងចំលើយឈ្មោះគសក (ជាចុងបណ្តឹងសាទុក្ខ)ភេទស្រីអាយុ៦៣ឆ្នាំ ជាតិខ្មែរ ទីលំនៅ ភូមិស្ទឹងថ្មី ឃុំស្វាយដង្គំ ស្រុមសៀមរាប ខេត្តសៀមរាប ។ ផ្ទេរសិទ្ធិឱ្យឈ្មោះលីន សំភាស អាយុ៤៩ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិ ផ្សារលិច ឃុំព្រែកញ្ចៀ ស្រុកពញាឮ ខេត្តកណ្តាល ។

**មេធាវី លោក ..............**

តតិយជនៈ លោកលី ហុក អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។

កម្មវត្ថុបណ្តឹងៈ ប្តឹងសុំទទួលស្គាល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស-រ០០៤៨៣៣ ចុះថ្ងៃទី២១-៦-០០ និងសុំឱ្យរុះរើតវ៉ាន់ចេញពីផ្ទះ ។

តាមបណ្តឹងសាទុក្ខលេខ៣៣០ ចុះថ្ងៃទី០៤-១១-០៣ របស់ឈ្មោះឡូវណារ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ១៤១(ឈ) ចុះថ្ងៃទី១៩-៩-០៣ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៧៩ ចុះថ្ងៃទី២៥-១២-០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី២០-០១-០៣ របស់ឈ្មោះឡូវណារ (ដើមចោទ) ប្តឹងសុំឱ្យទទួលស្គាល់ប័ណ្ណ សម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស-រ០០៤៨៣៣ ចុះថៃទី២១-០៦-០០ និង សុំឱ្យរុះរើឥវ៉ាន់ចេញពីផ្ទះ ដោយហេតុថា ខ្លួនបានគ្រប់គ្រងដីទំនាស់នេះតាំងពីឆ្នាំ១៩៨២ រហូត១៩៩៩ខ្លួនបានប្រកាសកាន់កាប់ដីនេះ រហូតបានធ្វើប័ណ្ណសម្គាល់ សិទ្ធិកាន់កាប់អចលនវត្ថុលខស.រ០០៤៨៣៣ ចុះថ្ងៃទី២១-០៦-០០ ។ ដោយខ្លួនខ្វះខាត ខ្លួនបាន លក់ផ្ទះនិងដីទៅឱ្យលី ហ៊ុក កាលពីថ្ងៃទី០៩-០៧-០២ ។ ឈ្មោះគសក ជាម្តាយខ្លួនបានឃាត់ឃាំងខ្លួនមិនឱ្យលក់ ព្រមទាំងឡើងទៅ រស់នៅលើផ្ទះរបស់ខ្លួនទៀត ។ កន្លងមកម្តាយខ្លួនមិនបានមកគ្រប់គ្រងដី និងផ្ទះនោះទេ ។

បានឃើញសាលក្រមលេខ១២៦ ចុះថ្ងៃទី២៤-០៦-០៣ របស់តុលាការខេត្តសៀមរាប ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី២០-០១-០៣ ទុកជាត្រឹមត្រូវតាមទម្រង់ ប៉ុន្តែបដិសេធចោលដោយផ្ទុយ នឹងគតិច្បាប់។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២៣-០១-០៣ របស់ដើមចោទឈ្មោះគីម សុភី ឱ្យទៅលោក លីន សំភាស ជាតំណាង ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

៣-បដិសេធសិទ្ធិកាន់កាប់ដីរបស់ដើមចោទឈ្មោះឡូវណារ និងប្តីឈ្មោះឯម សុភា ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុរលេខស-រ០០៤៨៣៣ ចុះថ្ងៃទី២១-០៦-០០ ទុកជាមោឃៈ។

៤-ទទួលស្គាល់ដីមួយប្លង់ទំហំ១៦អា០១ សង្ទីអា ស្ថិតនៅភូមិស្ទឹងថ្មី ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ដែលមានព្រំប្រទល់ខាងជើងទល់នឹងដីឈ្មោះគឹម សុំ និងផ្លូវ, ខាងត្បូងទល់នឹងដីហិន ថាច ខាងកើតទល់នឹងដីឈ្មោះឈិម ហាវ និងខាងលិចទល់នឹងដីឈ្មោះគឹម ស៊ុំ និងកែ បូផា ឈ្មោះគសក(ចុងចម្លើយ) មានសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិ ដោយមានលោកលីន សំភាស ជាតំណាង ។

៥-បង្គាប់ឱ្យឈ្មោះឡូវណារ (ដើមចោទ) និងប្តីឈ្មោះឯម សុភា សងសំណងថ្លៃដីចំនួន ៤៣,០០០ដុល្លារអាមេរិក(បួនម៉ឺនបីពាន់ដូដុល្លាអាមេរិក) និងជម្ងឺចិត្តចំនួន១០.០០០ដុល្លារអាមេរិក (មួយម៉ឺនដុល្លារអាមេរិក) ទៅឈ្មោះលីហ៊ុក ជាតតិយជនខាងដើមចោទ។ សុំលើសពីនេះលើកចោល ។

ក្នុងករណីគ្មានប្រាក់សងទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង បើរឹងរូសត្រូវដាក់គុកបង្ខំលើរូបកាយ ។

៦-សម្រេចរឹបអូសប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និងពន្ធហ៊្នឹង១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ បូករួម៧០០០៛ ។ ប្រាក់នេះបានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។ កាលបើហួសឧទ្ធរណ៍ត្រូវឱ្យដើមចោទបង់ពន្ធសមាមាត្រ១% លើទឹកប្រាក់ដែលតុលាការបានសម្រេចដែលត្រូវដាក់ចូលថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។ ពន្ធសមាមាត្រនេះត្រូវឱ្យចុងចម្លើយបង់ទុកមុនដែរ ទើបបង្គាប់ឲ្យដើមចោទសងទៅ ចុងចម្លើយវិញជាក្រោយ ។

៧-សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

សាលក្រមនេះត្រូវបានអ្នកស្រីឡូវណារ ប្តឹងឧទ្ធរណ៍តាមបណ្តឹង ចុះថ្ងៃទី០១-០៧-០៣ មិនសុខចិត្តនឹង សេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ១៤១ (ឈ) ចុះថ្ងៃទី១៩-០៩-០៣ របស់សាលាឧទ្ធរណ៍ ដែលសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-០៧-០៣ របស់ឈ្មោះឡវណារ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១២៦ ចុះថ្ងៃទី២៤-០៦-០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣,០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់៤៥០៛ រង្វាន់អ្នកប្រគល់ដីការកោះ៥០០០៛ ចំណាយលើអង្គាធរតុលាការ៥០០០៛ សរុប ១៣០០០៛ ។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៨-០៩-០៣ចំពោះមុខគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩-០៩-០៣ ចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៣៣០ ចុះថ្ងៃទី០៤-១១-០៣ របស់អ្នកស្រីឡវណារ ស្ថិតនៅក្នុងកំណត់ ច្បាប់។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា សាលដីការដ្ឋប្បវេណីលេខ១៤១(ឈ)ចុះថ្ងៃទី១៩-០៩-០៣ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ។

បានស្តាប់ចម្លើយរបស់អ្នកស្រីឡវណារ នាពេលសវនាការថាៈដីនេះខ្លួនជាអ្នករស់នៅតាំងពីឆ្នាំ១៩៨២ ដោយមានរដ្ឋអំណាចភូមិ-ឃុំដឹងឮ រហូតដល់ពេលខ្លួនលក់ដី ។

បានស្តាប់ចម្លើយរបស់លោកលីន សំភាស នាពេលសវនាការថាៈ ខ្លួនសុំជំទាស់នឹងចម្លើយរបស់ឡែម រ៉ាអំណាក់ ដែលជាទៅរស់នៅលើដីទំនាស់នៅឆ្នាំ១៩៨២ ។

ក្រោយឆ្នាំ១៩៧៩ លោកយាយគសក បាននាំកូន៣នាក់មកកាប់ឆ្ការ និងសង់ខ្ទមដើម្បីរស់នៅលើដីទំនាស់នេះ

-សំណូមពរសុំបដិសេធ ប្រកាសកាន់កាប់ដីធ្លីរបស់ ឡវណារ ។

-សុំតម្កល់សាលក្រម និងសាលដីកាតុលាការថ្នាក់ក្រោម ទុកជាបានការ ។

-ឯចម្លើយដែលឡវណារ ថាគាត់មិនដែលទៅរស់នៅបាត់ដំបងនោះជាការមិនពិតទេ ។

-លោកយាយគសក សុំសីលនៅឆ្នាំ១៩៨០ ហើយបួសនៅឆ្នាំ១៩៩៩ ។

អ្នកស្រីឡវណារ ឆ្លើយបន្ថែមទៀតថា មករស់នៅភ្នំពេញខ្លួននៅមែន ឯទៅនៅបាត់ដំបងខ្លួនមិនដែលទៅនៅទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទឈ្មោះ............ ថាៈ កូនក្តីខ្លួនបានមករស់នៅនិងកាប់ឆ្ការនៅឆ្នាំ១៩៨២ ឯគសក មិនបានរស់នៅជាប់លាប់លើដីនេះទេ ។

អ្នកស្រីគសក បានមកម្តងម្កាលប៉ុណ្ណោះ គាត់ខ្លួនឯងក៏ទទួលស្គាល់ដែរ នៅតុលាការខេត្ត ។ ការធ្វើប្លង់របស់កូនក្តីខ្លួនគឺត្រឹមត្រូវតាមច្បាប់ ឯលិខិតស្នើសុំកាន់កាប់ដីរបស់គសក គឺមិនត្រឹមត្រូវតាមច្បាប់ទេព្រោះមានការផ្តិតមេដៃជំនួសហើយដាក់ឈ្មោះគសក ។.

សុំបដិសេធសាលក្រមតុលាការខេត្តសៀមរាប និងសាលដីកាសាលាឧទ្ធរណ៍ទាំងមូល និងសុំទទួលស្គាល់លិខិត ទិញ-លក់របស់កូនក្តីខ្លួន និងតតិយជន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី ចុងចម្លើយឈ្មោះលឹម អេងរតនៈ ថា ក្រោយឆ្នាំ១៩៧៩ អ្នកស្រីគសក វិលមកកាប់ឆ្ការ និងសង់ខ្ទមរស់នៅលើដីកេរ្តិ៍នវិញ ហើយបានទាំងរៀបការប្តីឱ្យឡវណារ ទៀតផង ។

នៅឆ្នាំ១៩៩៣ គាត់បានទិញដីឱ្យឡវណារ តែឈ្មោះនេះមិននៅបែរជាលក់ឱ្យគេបាត់ ។ ឆ្នាំ១៩៨៩ រដ្ឋប្រកាសឱ្យដាក់ពាក្យសុំកាន់កាប់ដីធ្លីតែឡវណារ ដែលអះអាងថាខ្លួនជាអ្នកកាន់កាប់តែហេតុអ្វីមិនដាក់ពាក្យសុំ តែបែរជាមកដាក់ពាក្យកាន់កាប់នៅឆ្នាំ២០០០ វាខុសគ្នាឆ្ងាយពេក ។ តែផ្ទុយទៅវិញឆ្លៀតពេលម្តាយសុំសីលលួចធ្វើប័ណ្ណ កម្មសិទ្ធិ ។

សំណូមពរសុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល និងសុំឱ្យទទួលស្គាល់បង្កន់ដៃសំកាន់កាប់ដីរបស់លោកយាយ គសក ។

សុំបដិសេធពាក្យសុំកាន់កាប់ដីរបស់ឡវណារ ។

មេធាវី............ បានសន្និដ្ឋានបន្ថែមទៀតថា ឆ្នាំ២០០០ គឺសុំប័ណ្ណកម្មសិទ្ធិ មិនមែនដាក់ពាក្យសុំកាន់កាប់ដីនោះទេ ។

មេធាវីលឹម អេងរតនៈ សន្និដ្ឋានតបថា នៅឆ្នាំ២០០០ នោះឡវណារ ដាក់ពាក្យស្នើសុំកាន់កាប់ដីធ្លីផង និងដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិផង គឺធ្វើនៅក្នុងឆ្នាំតែ ១ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវី គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៣៣០ ចុះថ្ងៃទី០៤-១១-០៣ របស់អ្នកស្រីឡវណារ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា សារណាចុះថ្ងៃទី០៦-១០-០៣ របស់អ្នកស្រីឡវណារ ថាឆ្នាំ១៩៨២ ខ្លួនបានកាប់ឆ្ការព្រៃ មានអាជ្ញាធរដឹងឮ ពុំមានជនណាជំទាស់ទេ ចុងចម្លើយត្រឡប់មកធ្វើផ្ទះឱ្យខ្លួនរស់ នៅលើដីទំនាស់នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថាៈ មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថានៅឆ្នាំ១៩៧៩ ចុងចម្លើយជាម្តាយបាននាំកូន៣នាក់(រួមទាំងដើមចោទផង) មកសង់រោងរស់នៅលើដីទំនាស់ដែលជាដីកេរ្តិ៍របស់ខ្លួនពីសង្គមមុន ដោយបានរៀបការដើមចោទនៅលើដីទំនាស់នេះតាំងពីឆ្នាំ១៩៨០ ឬ ១៩៨៤ រហូតដល់ឆ្នាំ១៩៩៣ ទើបម្តាយដើមចោទបានហៅ ដើមចោទមករស់នៅលើផ្ទះរបស់ខ្លួនដែលបានសង់អំពីឈើរួចហើយ ។ ដូច្នេះចុងចម្លើយនៅតែមានសិទ្ធិលើដី និងផ្ទះទំនាស់នេះតាមមាត្រា២ និង មាត្រា ៥ នៃអនុក្រឹត្យលេខ២៥ អនក្រ ចុះថ្ងៃទី២២-០៤-៨៩ ដដែល ។ ម្យ៉ាងទៀតនៅឆ្នាំ១៩៧៩ ដើមចោទទើបតែ មានអាយុ១៧ ឆ្នាំប៉ុណ្ណោះ ។

-យល់ឃើញថា ការដែលដើមចោទ និងមេធាវីដើមចោទលើកឡើងនៅក្នុងសារណា និងនៅក្នុងពេលសវនាការនេះថាដើមចោទបានរស់នៅលើដីនិងផ្ទះទំនាស់នេះជាប់លាប់ពុំដែលអាក់ខាននោះជាការពុំត្រឹមត្រូវទេពីព្រោះថាៈ

តាមអត្តសញ្ញាណលេខ០៥១៦២៣កព ចុះថ្ងៃទី០៤-០២-៨៥ បញ្ជាក់ថាអ្នកស្រីឡវណារ មានលំនៅអចិន្ត្រៃយ៍ផ្ទះលេខ៧៣៩ ផ្លូវសឹងង៉ុកមិញ ខណ្ឌចំការមន ក្រុងភ្នំពេញ ពុំមែនរស់នៅលើដីនិងផ្ទះជំទាស់ទេ។

-នៅពេលសវនាការសាលាឧទ្ធរណ៍ដើមចោទក៏បានទទួលស្គាល់ថា ខ្លួនទើបតែត្រឡប់មករស់នៅលើដីទំនាស់នេះវិញនៅឆ្នាំ១៩៩៣ ទេ ។

-យល់ឃើញថា ការដែលដើមចោទលើកឡើងក្នុងសារណា និងក្នុងពេលសវនាការនេះថាចុងចម្លើយជាម្តាយរបស់អ្នកស្រីពុំបានរស់នៅលើដីនិងផ្ទះទំនាស់ទេនោះ ជាការពុំត្រឹមត្រូវទេពីព្រោះថា -

-តាមអត្តសញ្ញាណប័ណ្ណលេខ២២៨៦៦៧សរ ចុះថ្ងៃទី០៥-០៩-៩២ របស់អ្នកស្រីគសភ បញ្ជាក់ថា អ្នកស្រីមានទីលំនៅអចិន្ត្រៃយ៍នៅលើដីទំនាស់នេះតែម្តង ។

-ការដែលអ្នកស្រីគឹមសុភីចាកចេញពីផ្ទះទៅសំណាក់ធម៌នៅឯវត្ត ពុំអាចចាត់ទុកថាជាការបោះបង់ ចោលទីលំនៅទេ ។

-យល់ឃើញថា ការដែលដើមចោទ និងមេធាវីលើកឡើងថា ដីទំនាស់នេះត្រូវជានអាជ្ញាធរជំនាញធ្វើការអង្កេត និងចេញប័ណ្ណសម្គាល់សិទ្ធិឱ្យត្រឹមត្រូវហើយនោះជាការពុំត្រឹមត្រូវទេ ពីព្រោះដី និងផ្ទះទំនាស់នេះចុងចម្លើយជាអ្នកកាន់កាប់គ្រប់គ្រងចាត់ចែងតាំងពីឆ្នាំ១៩៧៩ មកពុំដែលអាក់ខានទេ ដោយបានដាក់ពាក្យសុំកាន់កាប់ និងមានបង្កាន់ដៃទទួល ពាក្យសុំកាន់កាប់តាំងពីឆ្នាំ១៩៨៩ មករីឯដើមចោទទើបតែធ្វើប័ណ្ណសម្គាល់សិទ្ធិនៅឆ្នាំ២០០០ ដោយពុំមានការយល់ព្រម និងដឹងឮពីចុងចម្លើយ ។ ដូច្នេះប័ណ្ណនេះពុំមានសុពលភាពអាចយកមកប្រើប្រាស់បានទេ ។

-យល់ឃើញថា ការដែលមេធាវីដើមចោទបានលើកឡើងថា ពាក្យសុំកាន់កាប់ដីធ្លីចុះថ្ងៃទី២៧-១០-៨៩ របស់ចុងចម្លើយពុំមែនជាស្នាមមេដៃរបស់ចុងចម្លើយនោះពុំមែនជាមូលហេតុនាំឱ្យបាត់បង់សិទ្ធិរបស់ចុងចម្លើយលើដី និងផ្ទះទំនាស់ទេ ពីព្រោះទាំងរដ្ឋអំណាច ទាំងចុងចម្លើយ ទាំងសាក្សី បានទទួលស្គាល់ថាដីទំនាស់ និងផ្ទះពិតជាកាន់កាប់គ្រប់គ្រងដោយចុងចម្លើយប្រាកដមែន ។ ម្យ៉ាងទៀតចុងចម្លើយក៏បានឆ្លើយដូចគ្នា និងប្រធានក្រុមដែរថាខ្លួនមិនចេះអក្សរទើបឱ្យប្រធានក្រុមធ្វើពាក្យសុំកាន់កាប់ដីនេះឱ្យ ។

-យល់ឃើញថា ការដែលដើមចោទធ្វើប័ណ្ណកម្មសិទ្ធិដីរបស់ចុងចម្លើយហើយយកទៅលក់ឱ្យអ្នកដទៃតាមមាត្រ ៣៥ នៃក្រិត្យច្បាប់លេខ៣៨ ក្រច ចុះថ្ងៃទី២៨-១០-៨៨ ការលក់-ទិញនេះត្រូវទុកជាមោឃៈ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៤១(ឈ) ចុះថ្ងៃទី១៩-៩-០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ៣៣០ ចុះថ្ងៃទី០៤-១១-០៣ របស់អ្នកស្រីឡវណារ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ១៤១(ឈ) ចុះថ្ងៃទី១៩-០៩-០៣ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញ ទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលចុងចម្លើយបានបង់ជួសនៅតុលាការកំពូលចំនួន១៩០០០រៀល គឺៈ

-ពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន៤០០០រៀលប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ .

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន១៥០០០រៀល សរុប ១៩០០០រៀល ហើយតម្រូវឱ្យដើមចោទ សងប្រាក់ចំនួន១៩០០០៛ នេះទៅចុងចម្លើយវិញ ។

បង្គាប់ឱ្យដើមចោទ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តសៀមរាប ។

៥-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៤ ។